សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៣៦

ចុះថ្ងៃទី ០៣_០៣_១០

សាលដីកា

លេខ : ០៣ "ក្រVI អ"

ចុះថ្ងៃទី ២៧_០១_២០១១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក សេង ប៊ុនថេន

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៦ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១០ រវាង:

- ជនជាប់ចោទឈ្មោះ [redacted] ឃិន ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅ [redacted] ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរពាយ៉ើជួសជុល ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ទោសពីមុនមាន ចាប់ខ្លួនថ្ងៃទី ១០-១២-២០០៨ ឃុំខ្លួនលេខ ២១៦៨ តព្រ ចុះថ្ងៃទី ១៨-១២-២០០៨។

មានលោកស្រី [redacted] ចិត្រា ជាមេធាវីការពារ។



Scanned by CamScanner

៤ (១/៤)

<u>ជាប់ចោទពីបទៈ</u> ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤-០១-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥០. ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាវេត ភេទប្រុស អាយុ ៦០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១២៤ ផ្លូវលេខ ១០១៩ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៣ ឈ្មោះ [redacted] **យិន** និងពួកខ បានធ្វើកិច្ចសន្យាទិញ និងលក់ដីក្លែងក្លាយ ដោយបានក្លែងស្នាមមេដៃ និងក្លែងដាក់ឈ្មោះ[redacted]**សាវេត** ថា បានលក់ដីនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ មកឱ្យខ្លួនឈ្មោះ [redacted]**យិន** រួចយកលិខិតក្លែងនោះទៅប្តឹងតុលាការក្រុងភ្នំពេញ ដើម្បីឱ្យតុលាការសម្រេចប្រគល់ដីឱ្យខ្លួនធ្វើជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៦ ឆ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសឈ្មោះ[redacted] **យិន** ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារសរុបកំណត់ ៤ឆ្នាំ (បួនឆ្នាំ) គិតបន្តពីសាលក្រមមុន និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០រៀល (បួនលានរៀល) សម្រាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨-០៤-២០០៤, ១៩-០៥-២០០៤, ១០-០៣-១៩៩៣ និង ១០-០៤-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាម បញ្ញត្តិមាត្រា ៥០. ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- បង្គាប់ឱ្យឈ្មោះ[redacted] **យិន** សងថ្លៃខូចខាត និងជម្ងឺចិត្តចំនួន ៤០.០០០.០០០រៀល (សែសិបលានរៀល) ទៅឱ្យឈ្មោះ[redacted] **សាវេត** ដែលមានលោក[redacted]បូរ៉ាវុធ ជាមេធាវីតំណាង ។ ការសុំលើសពីនេះត្រូវច្រានចោល ។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨១ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញវិញ ដើម្បីបើកការស៊ើបសួរលើពួកខ និងចាត់ការតាមនីតិវិធី ។

៤- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។



Scanned by CamScanner

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] យិន ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៦ «ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហារយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោ[redacted]យិន (វត្តមាន)

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវៃត ( អវត្តមាន)

- លោកស្រី [redacted]ធីតា ជាមេធាវីការពារជនជាប់ចោទ( វត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] យិន ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកដោយតុលាការក្រុងភ្នំពេញដាក់ទោសខ្លួនធ្ងន់ពេក ហើយការទិញដី និងលុយកាក់ទិញដី គឺតាមរយ:ឈ្មោះ [redacted] រេង ហើយខ្លួនពុំដែលប្រគល់លុយឱ្យទៅម្ចាស់ដីផ្ទាល់ទេ ។ សំណូមពរ សុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: សំណូមពរ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

លោកស្រី [redacted]ធីតា ជាមេធាវីការពារជនជាប់ចោទធ្វើការការពារថា: សំណូមពរ សុំឱ្យក្រុមប្រឹក្សាមេត្តាពិចារណាស្រួបទោសឱ្យកូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអបាអយ្យការអមសាលាឧទ្ធរណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

- ក្រោយពីបានពិនិត្យពិភាក្សានិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]យិន ធ្វើឡើងក្នុងកំណត់ច្បាប់សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តាមអង្គហេតុបញ្ជាក់ថា កាលពីថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៣ ឈ្មោះ [redacted] យិន និងពួកបានធ្វើកិច្ចសន្យាទិញ និងលក់ដីក្លែងក្លាយ ដោយដាក់ឈ្មោះ[redacted]សាវៃត ថា បានលក់ដីឱ្យខ្លួន ហើយក៏បានយកលិខិត



Scanned by CamScanner

នោះទៅប្ដឹងតុលាការក្រុងភ្នំពេញ ដើម្បីបំភាន់តុលាការ រួចហើយឱ្យតុលាការចេញសាលក្រមដើម្បីយកដីនោះទៅ លក់ឱ្យអ្នកផ្សេងទៀត ។

៣- តាមចម្លើយឈ្មោះ [redacted] សាវៃត ជាដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយបញ្ជាក់ថា កិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្ដាច់ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ១៩៩៣ ថា ខ្លួនជាអ្នកលក់ដីឱ្យឈ្មោះ [redacted] ឃិន ប៉ុន្តែតាមការពិតខ្លួនមិនដែលបានផ្ដិតមេដៃលក់ដី និងទទួលប្រាក់ពីឈ្មោះ [redacted] ឃិន ឡើយ នេះបញ្ជាក់ថា លិខិតទាំងពីរដែលឈ្មោះ [redacted] ឃិន ធ្វើឡើងនេះ គឺជាឯកសារក្លែងក្លាយទាំងស្រុង ។

៤- លិខិតប្រគល់ប្រាក់ផ្ដាច់ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ១៩៩៣ និងកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៣ រវាងអ្នកលក់ឈ្មោះ [redacted] សាវៃត និងអ្នកទិញឈ្មោះ [redacted] ឃិន គឺជាឯកសារក្លែងក្លាយទាំងអស់ ។

៥- តាមការយល់ឃើញខាងលើ និងភស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ឃិន ពីបទ ផ្ដល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០ ខែមេសា ឆ្នាំ១៩៩៣ និងថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៥០. ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៦- រឿងក្ដីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៧- សាលក្រមព្រហ្មទណ្ឌលេខ ៤៦ ជ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

**ហេតុដូច្នេះ សាលាឧទ្ធរណ៍**

**វិនិច្ឆ័យសេចក្ដី**

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ឃិន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយគ្មានមូលដ្ឋានគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៦ ជ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងស្រុង ។

៣- បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ឃិន តាមនីតិវិធីច្បាប់ ។

៤- សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១១ កំបាំងមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ ។

បើកសិទ្ធិឱ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍, ថ្ងៃទី 09 ខែ 02 ឆ្នាំ២០១១

ក្រឡាបញ្ជី

S. Buthan

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]